LIVERPOOL HOSPITAL

NSW GOVERNMENT | Health South Western Sydney Local Health District

KHMER

# ការបែងចែកពេលសម្អាតពោះវៀនដើម្បីឆ្លុះពិនិត្យផ្ទៃក្នុងពោះវៀនធំ ដោយប្រើថ្នាំ MOVIPREP - បញ្ជីពេលព្រឹក (Split Bowel Preparation Colonoscopy using MOVIPREP – MORNING LIST)

## មួយសប្តាហ៍មុនការឆ្លុះពិនិត្យផ្ទៃក្នុងពោះវៀនធំរបស់អ្នក៖ ការត្រៀមខ្លួន

1. **ទិញថ្នាំ Moviprep មួយប្រអប់** (មាន៖ 2 កញ្ចប់ - កញ្ចប់នីមួយៗមានកញ្ចប់តូច A និង B) ពីឱសថស្ថានក្នុងតំបន់របស់អ្នក (មិនចាំបាច់មានវេជ្ជបញ្ជាទេ)។
2. **ឈប់**លេបគ្រាប់ថ្នាំជាតិដែក Imodium/Lomotil/Gastrostop។
3. ប្រសិនបើអ្នកប្រើថ្នាំធ្វើឱ្យឈាមរាវ ដូចជា Warfarin, Pradaxa (Dabigatran), Xarelto (Rivaroxaban), Eliquis (Apixaban), Brilinta (Ticagrelor), Plavix, Iscover ឬ Piax (Clopidogrel) សូមជូនដំណឹងដល់គិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នក។ អ្នកអាចបន្តប្រើថ្នាំអាស្ពីរីន ក្នុងអំឡុងពេលឆ្លុះពិនិត្យផ្ទៃក្នុងពោះវៀនធំ។
4. ប្រសិនបើអ្នកលេបថ្នាំការពារជំងឺទឹកនោមផ្អែម សូមជូនដំណឹងដល់គិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នក។
5. ប្រសិនបើអ្នកមានជំងឺខ្សោយបេះដូង ថ្លើម ឬតម្រងនោម សូមជូនដំណឹងដល់គិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នក។ ការសម្អាតពោះវៀននេះ ប្រហែលជាមិនសមស្របចំពោះអ្នកទេ។
6. ប្រសិនបើអ្នកប្រើថ្នាំបញ្ចុះលាមកជាទៀងទាត់ សូមបន្តប្រើថ្នាំនេះ។

## បីថ្ងៃមុនការឆ្លុះពិនិត្យផ្ទៃក្នុងពោះវៀនធំរបស់អ្នក៖ កែប្រែរបបអាហាររបស់អ្នក

**ជៀសវាង**អាហារដែលមានសារជាតិសរសៃខ្ពស់ ដូចជាគ្រាប់ធញ្ញជាតិទាំងមូល នំប៉ុងធ្វើពីគ្រាប់ស្រូវសាលីទាំងមូល និងគ្រាប់ធញ្ញជាតិ គ្រាប់ផ្លែឈើ (nuts) គ្រាប់ពូជ(seeds) ពពួកសណ្តែក  ផ្លែឈើស្រស់ និងស្ងួត សាឡាត់ និងបន្លែឆ្អិន ហើយនិងអាហារមានជាតិខ្លាញ់ទាំងអស់។

អាហារ**តំរូវ**ដែលមានសារជាតិសរសៃទាបត្រូវបានអនុញ្ញាតឱ្យបរិភោគ រួមមាននំប៉ុងស នំប៉ុងអាំង ស៊ុបថ្លា ឈីស សាច់ភ្លៅជ្រូក ស៊ុត ត្រីធូណា សាច់មាន់ សាច់គ្មានជាតិខ្លាញ់ ត្រី ដំឡូងបារាំង បាយអង្ករស ល្ពៅ និងការ៉េម។

## មួយថ្ងៃមុនការឆ្លុះពិនិត្យផ្ទៃក្នុងពោះវៀនធំរបស់អ្នក៖ សម្អាតពោះវៀនធំរបស់អ្នកជាមួយថ្នាំ MOVIPREP

### <u>នៅថ្ងៃនេះ - ផឹកតែវត្ថុរាវថ្លាប៉ុណ្ណោះ មិនត្រូវពិសាអាហាររឹងទេ</u>

ផឹកតែវត្ថុរាវថ្លាដែលបានយល់ព្រមប៉ុណ្ណោះ ទឹក ស៊ុបថ្លា ស៊ុបមាន់ថ្លា ទឹកផ្លែឈើ ចាហួយ តែខ្មៅ និងកាហ្វេ (កុំពិសាទឹកដោះគោ ឬផលិតផលធ្វើពី ទឹកដោះគោ) ភេសជ្ជៈកីឡា ភេសជ្ជៈកាបូណាត  វត្ថុលាយសម្រាប់ផឹកជំនួសការបាត់បង់ជាតិអំបិល និងទឹក (oral rehydration salts) ឧទាហរណ៍ *Hydrolyte* និង *ORS*។ ផឹកវត្ថុរាវថ្លា *ឱ្យបានយ៉ាងហោចណាស់* 10 កែវ ដើម្បីរក្សាជាតិទឹកក្នុងដងខ្លួន។

**ម៉ោង 5 ល្ងាច (ប្រហែល)៖ កម្រិតដំបូងនៃថ្នាំ Moviprep៖**







បន្ថែមចំណុះកញ្ចប់ទាំងមូល (មានកញ្ចប់តូច A និង B) ក្នុងទឹកក្តៅឧណ្ហៗ 1 លីត្រ ហើយកូររហូតដល់រលាយ។
ដាក់ក្នុងទូទឹកកកឱ្យត្រជាក់ រយៈពេលកន្លះម៉ោងមុននឹងផឹក។

ផឹករវត្ថុលាយនេះយឺតៗ ប៉ុន្តែតែឱ្យបានអស់ទាំងស្រុងក្នុងរយៈពេល 2 ទៅ 3 ម៉ោងបន្ទាប់។

ការសម្អាតពោះវៀននេះអាចបណ្តាលឱ្យមានការចុះរាគច្រើនដងក្នុងរយៈពេល 2 ទៅ 3 ម៉ោង បន្ទាប់ពីបានផឹកកម្រិតថ្នាំដំបូង។

ការចុះរាគចំពោះបុគ្គលម្នាក់ៗអាចកើតមានខុសគ្នា។ រក្សានៅទីកន្លែងដែលអាចទៅបង្គន់បានដោយងាយស្រួល។

## នៅថ្ងៃឆ្លុះពិនិត្យផ្នែកខាងក្នុងពោះវៀនធំរបស់អ្នក

**ម៉ោង 4 ព្រឹក កម្រិតថ្នាំទីពីរ៖** សូមធ្វើតាមការណែនាំដូចកម្រិតថ្នាំទីមួយខាងលើ។

បន្តផឹករវត្ថុរាវថ្លា ហើយតមអាហារចាប់ពី**ម៉ោង 6 ព្រឹក។**

## ឈប់ផឹករវត្ថុរាវនៅម៉ោង 6 ព្រឹក

ប្រសិនបើអ្នកមានសំណួរណាមួយ អំពីការណែនាំស្តីពីការសម្អាតពោះវៀន
សូមទូរសព្ទមកមន្ទីរសិក្សាពីក្រពះពោះវៀន និងថ្លើម នៅមន្ទីរពេទ្យ Liverpool តាមទូរសព្ទលេខ 8738  4085។